**គោរពជូន**

**ឯកឧត្ដម ហោ ណាំហុង**

**ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ**

**នៃព្រះរាជាណាចក្រកម្ពុជា**

ឯកឧត្តមជាទីគោរព

ខ្ញុំសូមចូលរួមរំលែកទុក្ខដ៏សែនក្រៀមក្រំជាទីបំផុតជាមួយព្រះរាជវង្សានុវង្ស រាជរដ្ឋាភិបាល និងប្រជាជន នៃព្រះរាជាណាចក្រកម្ពុជា ដោយបានទទួលដំណឹងដ៏សែនរន្ធត់ថា ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បានយាង ចូលព្រះទិវង្គត ។

ខ្ញុំសូមសម្តែងនូវមរណៈទុក្ខ និងការអាណិតអាសូរជាទីបំផុត ពីព្រោះការយាងចូលព្រះទិវង្គតរបស់ព្រះ មហាវីរក្សត្រដែលជាមគ្គុទ្ទេសក៏ដ៏ឈ្លាសវៃកម្រមាន ដែលបានខិតខំព្យាយាមបំពេញព្រះរាជកិច្ចអស់រយៈពេល មួយជីវិតរបស់ព្រះអង្គ ដើម្បីស្វែងរកឯករាជ្យ សន្តិភាព និងស្ថិរភាពជូនព្រះរាជាណាចក្រកម្ពុជា គឺជាប្រការគួរឱ្យ សោកស្តាយជាទីបំផុតមិនមែនសំរាប់តែប្រទេសកម្ពុជាប៉ុណ្ណោះទេ ក៏ប៉ុន្តែថែមទាំងសម្រាប់សហគមន៍អន្តរជាតិ ជាពិសេសប្រទេសរបស់យើងខ្ញុំ ដែលបានចូលរួមចំណែកក្នុងការស្វែងរកសន្តិភាព និងការកសាងឡើងវិញនូវ ប្រទេសកម្ពុជា ផងដែរ ។

ខ្ញុំសូមរំឭកនូវស្នាព្រះហស្តនៃព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដី និងឯកភាព ជាតិខ្មែរ និងសូមបួងសួងសូមឱ្យព្រះវិញ្ញាណក្ខន្ធព្រះអង្គបានទៅកាន់សុខគតិភព ព្រមទាំងសូមឱ្យព្រះរាជវង្សា នុវង្ស រាជរដ្ឋាភិបាល និងប្រជាជន នៃព្រះរាជាណាចក្រកម្ពុជាបានឆ្លងផុតពីឱកាសដ៏មហាសោកសៅនេះ និងសូម ឱ្យប្រទេសកម្ពុជាបានសម្រេចនូវការអភិវឌ្ឍន៍ថែមទៀតជាបន្តបន្ទាប់ ។

ថ្ងៃទី ១៥ ខែតុលា ឆ្នាំ ២០១២

ហ្គេមបា កូអ៊ីជីរ៉ូ

រដ្ឋមន្ត្រីការបរទេស នៃប្រទេសជប៉ុន